ក្រុមមេធាវី ខេមឡ
CAMLAW GROUP

# ច្បាប់
# ស្តីពី
# ការត្រួតពិនិត្យ
# ផលិតផលថ្នាំជក់

## ២០១៥

# ព្រះរាជក្រម

នស/រកម/០៥១៥/០០៤

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖



www.pheakdeylaw.com

# ច្បាប់
# ស្តីពី
# ការត្រួតពិនិត្យ
# ផលិតផលថ្នាំជក់

២/១៥

www.pheakdeylaw.com

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងការពារសុខភាពសាធារណៈ និងកាត់បន្ថយផលប៉ះពាល់ដល់សុខភាព សេដ្ឋកិច្ច សង្គម និងបរិស្ថាន ដែលបណ្តាលមកពីផលិតផលថ្នាំជក់ ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅដូចតទៅ ៖

- កំណត់វិធានការក្នុងការគ្រប់គ្រង និងត្រួតពិនិត្យផលិតផលថ្នាំជក់ ។
- លើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សាធារណជន អំពីគ្រោះថ្នាក់នៃការប្រើប្រាស់ផលិតផលថ្នាំជក់
- សហការជាមួយបណ្តាក្រសួង ស្ថាប័នជាតិ អន្តរជាតិ និងអង្គការដៃគូនានា ដើម្បីជំរុញការអប់រំ និងកាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់ ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តលើគ្រប់សកម្មភាពពាក់ព័ន្ធនឹងផលិតផលថ្នាំជក់គ្រប់ប្រភេទដែលផលិតនៅក្នុងស្រុក ឬនាំចូលពីបរទេស ហើយចែកចាយ លក់ និងប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចតទៅ ៖

- **ផលិតផលថ្នាំជក់** សំដៅដល់ផលិតផលគ្រប់ប្រភេទផ្សំឡើងពីសន្លឹកថ្នាំជក់ សរសៃថ្នាំជក់ ឬសារធាតុនៃថ្នាំជក់ដែលផលិតដោយឧស្សាហករថ្នាំជក់ ឬដោយមធ្យោបាយផ្សេងៗទៀតដែលប្រើប្រាស់សម្រាប់ជក់ដោយផ្ទាល់ ឬដោយទម្រង់ផ្សេងៗទៀត រួមមាន ជញ្ជក់ ទំពា បុក ឬហិត ។
- **ឧស្សាហករថ្នាំជក់** សំដៅដល់ផលិតករថ្នាំជក់ អ្នកលក់ដុំ និងអ្នកនាំចូលផលិតផលថ្នាំជក់ ។
- **ការឧបត្ថម្ភធីដោយឧស្សាហកម្មថ្នាំជក់** សំដៅដល់រាល់ទម្រង់នៃភាគទានចំពោះព្រឹត្តិការណ៍ សកម្មភាព ឬបុគ្គលណាមួយ ដោយមានគោលបំណងមានអានុភាពលើ ឬអាចមានអានុភាពលើការផ្សព្វផ្សាយផលិតផលថ្នាំជក់ ឬការប្រើប្រាស់ផលិតផលថ្នាំជក់ដោយផ្ទាល់ ឬដោយប្រយោល ។


www.pheakdeylaw.com

- កញ្ចប់ផលិតផលថ្នាំជក់ សំដៅដល់ប្រអប់ ក្រដាស គ្រឿងរុំពីក្រៅ ឬវត្ថុវេចខ្ចប់ផលិតផលថ្នាំជក់ ដោយមិនរាប់បញ្ចូលបារី ឬវត្ថុសម្រាប់ផ្ទុកផលិតផលថ្នាំជក់របស់កសិករ ។
- សារព្រមានសុខភាព សំដៅដល់សារជាភាសាខ្មែរ និងជារូបភាពដែលបោះពុម្ពលើកញ្ចប់ផលិតផលថ្នាំជក់ បង្ហាញពីគ្រោះថ្នាក់នៃការប្រើប្រាស់ថ្នាំជក់ និងព័ត៌មាន ពាក់ព័ន្ធផ្សេងទៀត ។
- គ្រឹះស្ថានសិក្សា សំដៅដល់មជ្ឈមណ្ឌលអប់រំ សិក្សា បណ្តុះបណ្តាល ដោយគិតចាប់ពីកម្រិតមត្តេយ្យសិក្សាដល់ឧត្តមសិក្សា ទោះជាប្រភេទសាលារៀន ឬវិទ្យាស្ថាន ឬសាកលវិទ្យាល័យ ឬមជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈគ្រប់កម្រិត ។
- គ្រឹះស្ថានសុខាភិបាល សំដៅដល់ប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព មន្ទីរពេទ្យ គ្លីនិកសុខភាពទាំងរដ្ឋ ទាំងឯកជន ឱសថស្ថាន មន្ទីរពិសោធន៍សុខាភិបាលជាដើម ។
- បរិយាកាសគ្មានផ្សែងថ្នាំជក់ សំដៅដល់ខ្យល់ដែលគ្មានផ្សែងថ្នាំជក់ ១០០% រួមទាំងខ្យល់ដែលមិនអាចមើលឃើញផ្សែងថ្នាំជក់ ធុំក្លិន ឬវាស់ស្ទង់បាន ។
- គ្រឹះស្ថានសាសនា សំដៅដល់ព្រះវិហារ ធម្មសភា សាលាបុណ្យ កុដិ បណ្ណាល័យ សាលា ពុទ្ធិកសិក្សា អាស្រម មណ្ឌលវិបស្សនា វិហារស៊ូរ៉ាវ ជាដើម ដែលទីកន្លែងទាំងនោះ ប្រើប្រាស់ក្នុងគោលបំណងគោរពបូជាសាសនាផ្សេងៗក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២
## សមត្ថកិច្ចត្រួតពិនិត្យថ្នាំជក់

### មាត្រា ៥.-

ក្រសួងសុខាភិបាលជាស្ថាប័នមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យរាល់សកម្មភាពពាក់ព័ន្ធនឹងផលិតផលថ្នាំជក់គ្រប់ប្រភេទដែលបញ្ញត្តក្នុងច្បាប់នេះ ។

### មាត្រា ៦.-

ក្រសួងសុខាភិបាលជាស្ថាប័នបង្គោលជាតិសម្រាប់ទំនាក់ទំនងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងបណ្តារដ្ឋភាគីនៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ របស់អង្គការសុខភាពពិភពលោក និងលេខាធិការដ្ឋាននៃអនុសញ្ញា ព្រមទាំងអង្គការជាតិ និងអង្គការអន្តរជាតិពាក់ព័ន្ធ ។



www.pheakdeylaw.com

**មាត្រា ៧.-**

រាជរដ្ឋាភិបាលត្រូវរៀបចំឲ្យមានគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ដើម្បីអប់រំ និង កាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់ ។

គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ត្រូវដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល និង មានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ត្រូវកំណត់ ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## ការបង្ហាញព័ត៌មានសមាសធាតុក្នុងផលិតផលថ្នាំជក់ និងការដាក់បង្ហាញសារព្រមានសុខភាព

**មាត្រា ៨.-**

ផលិតករក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយ និង លក់ ក្នុងករណីមានតម្រូវការចាំបាច់ត្រូវផ្តល់ជូនក្រសួងសុខាភិបាលនូវព័ត៌មានលម្អិតអំពីសមាសធាតុ ដែលមានក្នុងផលិតផលថ្នាំជក់ និងផ្សែងថ្នាំជក់ ។

ព័ត៌មានលម្អិតអំពីសមាសធាតុដែលមានក្នុងផលិតផលថ្នាំជក់ និងផ្សែងថ្នាំជក់ ត្រូវកំណត់ ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ៩.-**

ការប្រើប្រាស់ពាក្យដែលទាក់ទាញ និងធ្វើឲ្យយល់ច្រឡំ ជាអាទិ៍ ក្លិនឈ្ងុយឆ្ងាញ់ រសជាតិ ស្រាល រសជាតិស្រាលស្រទន់ រសជាតិវីតាមីន កាហ្វេអ៊ីនក្នុងផលិតផលថ្នាំជក់ ត្រូវហាមឃាត់ ។

**មាត្រា ១០.-**

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទ សម្រាប់ធ្វើការចែកចាយ លក់ និងប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ និង ជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់ អំពីគ្រោះថ្នាក់នៃការប្រើប្រាស់ផលិតផលថ្នាំជក់ ។

សារព្រមានសុខភាពជារូបភាព ត្រូវមានទំហំ ៥០ (ហាសិប) ភាគរយយ៉ាងតិច ។ ការបោះពុម្ព សារព្រមានសុខភាពជាអក្សរ និងរូបភាព ត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ជំពូកទី ៤
## វិធានការចំពោះការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីដោយឧស្សាហករថ្នាំជក់

**មាត្រា ១១.-**

ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់តាមប្រព័ន្ធផ្សព្វផ្សាយជារូបភាព ឬជាអក្សរ ឬជាសំឡេង តាមរយៈវិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្តី ស៊ីឌី វីស៊ីឌី ឌីវីឌី សេវាប្រៃសណីយ៍ សេវាទូរគមនាគមន៍ និងតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត ត្រូវហាមឃាត់ ។

ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ជាផ្ទាំងរូបភាព ផ្ទាំងប៉ាណូ ផ្ទាំងបដា ផ្ទាំងគំនូរ ឬបណ្ណផ្សព្វផ្សាយ ផលិតផលថ្នាំជក់ផ្សេងៗទៀតជាសាធារណៈ និងការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ជារូបភាពចល័ត នៅលើជញ្ជាំងរថយន្ត ឬលើយានជំនិះ និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ត្រូវហាមឃាត់ ។

ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ដល់សាធារណជននៅតាមទីកន្លែងសាធារណៈណាមួយ ដូចជាក្នុងកម្មវិធីប្រគំតន្ត្រី ឬកម្មវិធីកីឡា ឬកម្មវិធីផ្សេងៗទៀត និងការលើកកម្ពស់ការផ្សព្វផ្សាយផលិតផល ថ្នាំជក់ដល់អតិថិជនដោយផ្ទាល់ ឬដោយប្រយោល ដោយភ្នាក់ងារក្រុមហ៊ុនផលិតថ្នាំជក់ ត្រូវហាមឃាត់ ។

**មាត្រា ១២.-**

ចំពោះការដាក់តាំងបង្ហាញកញ្ចប់ផលិតផលថ្នាំជក់ធម្មតា អាចធ្វើទៅបានតែនៅនឹងកន្លែងលក់ ឬតូបលក់ ឬក្នុងហាងលក់បារីផ្ទាល់តែប៉ុណ្ណោះ ។

ទំហំ និងចំនួននៃកញ្ចប់ផលិតផលថ្នាំជក់ដែលដាក់តាំងបង្ហាញ ឬបិទនៅនឹងកន្លែងលក់ ឬតូបលក់ ឬក្នុងហាងលក់បារី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ១៣.-**

ការឧបត្ថម្ភកម្មវិធីក្នុងការប្រគំតន្ត្រី ឬកម្មវិធីកីឡា ឬកម្មវិធីជាសាធារណៈផ្សេងៗទៀត ជាផលិតផលថ្នាំជក់ ឬជាសម្ភារៈដែលបង្ហាញពីឈ្មោះផលិតផលថ្នាំជក់ត្រូវហាមឃាត់ ។

## ជំពូកទី៥
## ការចែកចាយ ការលក់ និងទីកន្លែងលក់ផលិតផលថ្នាំជក់

**មាត្រា ១៤.-**

ការគ្រប់គ្រង និងត្រួតពិនិត្យលើការលក់រាយ ការចែកចាយ និងការលក់ដុំផលិតផលថ្នាំជក់គ្រប់ប្រភេទ ត្រូវកំណត់ដោយអនុក្រឹត្យ ។


www.pheakdeylaw.com

**មាត្រា ១៥.-**

ការលក់ និងការចែកចាយផលិតផលថ្នាំជក់គ្រប់ប្រភេទដល់ជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និងស្ត្រីដែលមានគភ៌ ត្រូវហាមឃាត់ កាលបើគភ៌នោះ ត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើអ្នកលក់បានដឹង ។

ការលក់រាយមួយកញ្ចប់ក្រោម ២០ ដើម ត្រូវហាមឃាត់ ។

**មាត្រា ១៦.-**

រាល់ការនាំយកមកជាមួយខ្លួននូវបារី ឬផលិតផលថ្នាំជក់ដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន ចូលមកក្នុង ព្រះរាជាណាចក្រកម្ពុជា លើសពី ២០០ (ពីររយ) ដើម ឬស៊ីហ្គាលើស ៥០ (ហាសិប) ដើម ឬថ្នាំជក់ ទម្ងន់លើស ២៥០ (ពីររយហាសិប) ក្រាម ត្រូវហាមឃាត់ ។

ជនដែលមានអាយុតិចជាង ១៨ (ដប់ប្រាំបី) ឆ្នាំ មិនអនុញ្ញាតឲ្យនាំយកមកជាមួយខ្លួននូវ បារី ឬផលិតផលថ្នាំជក់ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

**មាត្រា ១៧.-**

ការលក់ និងចែកចាយផលិតផលថ្នាំជក់គ្រប់ប្រភេទ នៅក្នុងបរិវេណនៃគ្រឹះស្ថានសិក្សា គ្រឹះស្ថាន សុខាភិបាល សួនកុមារ គ្រឹះស្ថានសាសនា សារមន្ទីរ រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ កន្លែងហាត់ប្រាណ ស្ថានីយប្រេងឥន្ធនៈ និងកន្លែងងាយឆាបឆេះ ត្រូវហាមឃាត់ ។

ការលក់ផលិតផលថ្នាំជក់គ្រប់ប្រភេទ តាមមធ្យោបាយមិនផ្ទាល់ តាមរយៈម៉ាស៊ីនលក់ដោយ ស្វ័យប្រវត្តិ ការបញ្ជាទិញតាមប្រៃសណីយ៍ និងការបញ្ជាទិញតាមសេវាទូរគមនាគមន៍ផ្សេងៗ ត្រូវ ហាមឃាត់ ។

## ជំពូកទី ៦
## វិធានការការពារបរិយាកាស
## គ្មានផ្សែងផលិតផលថ្នាំជក់

**មាត្រា ១៨.-**

រាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ និងចាត់វិធានការការពារប្រជាពលរដ្ឋ ពីការប្រឈមនឹង ការស្រូបផ្សែងផលិតផលថ្នាំជក់ ដើម្បីធានាសិទ្ធិអ្នកមិនប្រើប្រាស់ផលិតផលថ្នាំជក់ ឲ្យទទួលបាន នូវបរិយាកាសដែលគ្មានផ្សែងផលិតផលថ្នាំជក់ ដើម្បីបង្ការនូវជំងឺផ្សេងៗដែលបណ្តាលមកពីការស្រូប ផ្សែងផលិតផលថ្នាំជក់ និងផលប៉ះពាល់ដល់សុខភាពដែលបង្កឡើងដោយផ្សែងផលិតផលថ្នាំជក់ ។

**មាត្រា ១៩.-**

វិធានការហាមការជក់ និងការបង្ហុយផ្សែងផលិតផលថ្នាំជក់ នៅកន្លែងធ្វើការ និងកន្លែង សាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ ។



www.pheakdeylaw.com

## ជំពូកទី ៧
## ការវាយតម្លៃអំពីហានិភ័យ ការតាមដាន ការត្រួតពិនិត្យ និងការសិក្សាស្រាវជ្រាវ

**មាត្រា ២០.-**

ក្រសួងសុខាភិបាលត្រូវសហការជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាឲ្យមានការវាយតម្លៃសមស្របអំពីហានិភ័យនៃសកម្មភាពទាក់ទងនឹងផលិតផលថ្នាំជក់ សម្រាប់ធ្វើការតាមដាន ត្រួតពិនិត្យ និងសិក្សាស្រាវជ្រាវអំពីផលប៉ះពាល់លើសុខភាព សេដ្ឋកិច្ច បរិស្ថាន និងសង្គម ។

**មាត្រា ២១.-**

ក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការសិក្សាស្រាវជ្រាវអំពីផលប៉ះពាល់ដល់សុខភាព សេដ្ឋកិច្ច បរិស្ថាន និងសង្គម ដោយផ្តោតលើការងារដូចខាងក្រោម ៖

- ការប្រើប្រាស់ផលិតផលថ្នាំជក់
- បរិមាណផលិតផលថ្នាំជក់ដែលនាំចេញ នាំចូល តម្លៃ និងការប្រើប្រាស់ថ្នាំជក់ វត្ថុធាតុដើម គ្រឿងម៉ាស៊ីន ប្រាក់ចំណូល ការដាំដំណាំថ្នាំជក់ និងព័ត៌មានផ្សេងៗទៀត
- ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយត្រួតពិនិត្យថ្នាំជក់ ។

**មាត្រា ២២.-**

ក្រសួងសុខាភិបាល និងស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំឲ្យមានក្រុមជំនាញវិទ្យាសាស្ត្រ និងមន្ទីរពិសោធន៍ ដើម្បីធ្វើតេស្តផលិតផលថ្នាំជក់ ជាពិសេស ស្តង់ដានៃសមាសធាតុ និងផលប៉ះពាល់ដែលកើតចេញពីការប្រើប្រាស់ផលិតផលថ្នាំជក់ ក្នុងករណីចាំបាច់ ត្រូវសហការជាមួយក្រុមជំនាញវិទ្យាសាស្ត្រ និងមន្ទីរពិសោធន៍ក្នុងតំបន់ និងអន្តរជាតិ ។

## ជំពូកទី ៨
## ការផ្តល់ព័ត៌មាន ការលើកកម្ពស់ ការយល់ដឹង និងការចូលរួមរបស់សាធារណជន

**មាត្រា ២៣.-**

ក្រសួងសុខាភិបាល គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ និងស្ថាប័នពាក់ព័ន្ធត្រូវលើកកម្ពស់ការយល់ដឹង ធ្វើការអប់រំ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់សាធារណជន អំពីផលប៉ះពាល់លើសុខភាព សេដ្ឋកិច្ច និងបរិស្ថានដែលបណ្តាលមកពីការប្រើប្រាស់ផលិតផលថ្នាំជក់ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·



www.pheakdeylaw.com

ក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ត្រូវសហការជាមួយ អាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល និងផ្នែកឯកជនដែលគ្មានទំនាក់ទំនងជាមួយ ឧស្សាហករថ្នាំជក់ដើម្បីជំរុញកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីផលវិបាកនៃការប្រើប្រាស់ផលិតផល ថ្នាំជក់ ។

**មាត្រា ២៤.-**

ក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ត្រូវសហការជាមួយ ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់សាធារណជន ក្នុងកម្មវិធីលើកកម្ពស់ការយល់ ដឹងជាសាធារណៈនៅទូទាំងប្រទេស តាមរយៈការអប់រំ និងយុទ្ធនាការផ្សព្វផ្សាយទូលំទូលាយ និង ជួយអ្នកប្រើប្រាស់ផលិតផលថ្នាំជក់ឲ្យឈប់ប្រើប្រាស់ផលិតផលថ្នាំជក់ ។

**មាត្រា ២៥.-**

អ្នកផ្តល់សេវាសុខាភិបាលគ្រប់ប្រភេទ ទាំងសាធារណៈ ទាំងឯកជន ត្រូវចូលរួម និងផ្តល់ការ អប់រំ ផ្សព្វផ្សាយអំពីផលវិបាកនៃការប្រើប្រាស់ផលិតផលថ្នាំជក់ ដល់សាធារណជន និងអតិថិជនរបស់ ខ្លួន ។

**មាត្រា ២៦.-**

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវបញ្ចូលកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីផលវិបាកនៃការ ប្រើប្រាស់ផលិតផលថ្នាំជក់ ទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ ទាំងសាធារណៈ និងឯកជន ។

**មាត្រា ២៧.-**

រាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ចំពោះកសិករ ដែលស្ម័គ្រចិត្តប្តូរការដាំដំណាំថ្នាំជក់ ទៅ ដំណាំផ្សេងវិញ ។

## ជំពូកទី ៩
## គោលនយោបាយពន្ធលើផលិតផលថ្នាំជក់

**មាត្រា ២៨.-**

រាជរដ្ឋាភិបាលត្រូវមានគោលនយោបាយដំឡើងពន្ធលើផលិតផលថ្នាំជក់គ្រប់ប្រភេទ ទៅតាម ស្ថានភាពសមស្រប ។

**មាត្រា ២៩.-**

រាជរដ្ឋាភិបាលត្រូវរៀបចំឲ្យមានមូលនិធិត្រួតពិនិត្យផលិតផលថ្នាំជក់ ដើម្បីកាត់បន្ថយការប្រើ- ប្រាស់និងផលប៉ះពាល់នៃការប្រើប្រាស់ថ្នាំជក់ អប់រំសុខភាព លះបង់ទម្លាប់ប្រើប្រាស់ផលិតផលថ្នាំ-

ជក់ ស្រាវជ្រាវ និងវាយតម្លៃកម្មវិធីត្រួតពិនិត្យផលិតផលថ្នាំជក់ និងសម្រាប់ជួយកសិករឱ្យលះបង់ការដាំដំណាំថ្នាំជក់ និងក្នុងគោលបំណងផ្សេងៗទៀត ដើម្បីបម្រើសុខភាពសាធារណៈ ។

មូលនិធិត្រួតពិនិត្យផលិតផលថ្នាំជក់នេះ ត្រូវបង្កើតដោយអនុក្រឹត្យ ។

## ជំពូកទី ១០
## អធិការកិច្ចផលិតផលថ្នាំជក់

**មាត្រា ៣០.-**

ក្រសួងសុខាភិបាលត្រូវចាត់តាំងមន្ត្រីជំនាញរបស់ក្រសួង ជាមន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ ដើម្បីតាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់នេះ ។

**មាត្រា ៣១.-**

ក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការទាក់ទងនឹងការធ្វើអធិការកិច្ចដែលមានចែងក្នុងច្បាប់នេះ មន្ត្រីអធិការកិច្ច ផលិផលថ្នាំជក់មានសិទ្ធិធ្វើការត្រួតពិនិត្យ និងចាត់វិធានការដូចខាងក្រោម ៖

- ធ្វើការត្រួតពិនិត្យជាប្រចាំទៅលើការប្រើប្រាស់ ការលក់ និងការផ្សព្វផ្សាយពាណិជ្ជកម្ម និងការបោះពុម្ពសារព្រមានសុខភាពលើផលិតផលថ្នាំជក់របស់ឧស្សាហករថ្នាំជក់
- ស្នើសុំត្រួតពិនិត្យ និងធ្វើតេស្តលើសមាសធាតុផលិតផលថ្នាំជក់ ដែលមាននៅក្នុងផលិតផលថ្នាំជក់ និងនៅក្នុងផ្សែងថ្នាំជក់
- ចាត់វិធានការហាមឃាត់ជាបណ្តោះអាសន្នចំពោះការចែកចាយ ឬការចរាចរ លើទីផ្សារនូវប្រភេទផលិតផលថ្នាំជក់ទាំងឡាយណាដែលបានស្រាវជ្រាវឃើញនូវសមាសធាតុដែលបង្កហានិភ័យខ្ពស់ក្នុងផលិតផលថ្នាំជក់ ឬបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះសុខភាពមនុស្ស និងបរិស្ថាន
- ត្រួតពិនិត្យ និងពិន័យអន្តរការណ៍ចំពោះការមិនអនុវត្តបទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យផលិតផលថ្នាំជក់
- ចាប់យកវត្ថុតាង និងបិទស្លាកបោះត្រាលើវត្ថុតាងនៃបទល្មើស
- បំពេញការកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

នីតិវិធីនៃការធ្វើអធិការកិច្ចផលិតផលថ្នាំជក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ៣២.-**

មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ ទទួលនីតិសម្បទាឲ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះ ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។



www.pheakdeylaw.com

**មាត្រា ៣៣.-**

រាល់ប្រតិបត្តិការពិនិត្យបទល្មើសរបស់មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។ មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ មានសិទ្ធិស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់ថ្នាក់ និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៣៤.-**

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ត្រូវស្លៀកពាក់ឯកសណ្ឋាន និងមានបណ្ណសម្គាល់ខ្លួន ព្រមទាំងមានលិខិតអនុញ្ញាតឲ្យបំពេញបេសកកម្ម ។

ឯកសណ្ឋាន និងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ៣៥.-**

បុគ្គលដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ អាចធ្វើបណ្តឹងតវ៉ាក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ ទៅរដ្ឋមន្ត្រីក្រសួងសុខាភិបាល គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច ឬថ្ងៃដកហូត ។

រដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវសម្រេចបណ្តឹងក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ គិតពីថ្ងៃទទួលពាក្យបណ្តឹង ។

ក្នុងករណីដែលបុគ្គលណាមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល បុគ្គលនោះមានសិទ្ធិធ្វើបណ្តឹងទៅតុលាការតាមនីតិវិធី ។

**មាត្រា ៣៦.-**

នៅពេលប្រតិបត្តិការអនុវត្តច្បាប់នេះ ក្នុងករណីវត្ថុតាងនៃបទល្មើសជាផលិតផលហាមឃាត់ ឬមានគ្រោះថ្នាក់ មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់មានសិទ្ធិស្នើសុំដីកាសម្រេចរបស់ព្រះរាជអាជ្ញា ដើម្បីធ្វើការបំផ្លាញចោលដោយអនុលោមតាមនីតិវិធីជាធរមាន ។

ការចំណាយលើការបំផ្លាញចោលវត្ថុតាងដូចមានចែងខាងលើ គឺជាបន្ទុករបស់ម្ចាស់វត្ថុតាងនៃបទល្មើស ។

**មាត្រា ៣៧.-**

ប្រាក់ពិន័យអន្តរការណ៍ត្រូវបង់ចូលថវិការដ្ឋ ។ រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តមន្ត្រី ដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសជាក់លាក់ណាមួយដែលចែងក្នុងច្បាប់នេះ ។



www.pheakdeylaw.com

## ជំពូកទី ១១
## ទោសប្បញ្ញត្តិ

**មាត្រា ៣៨.-**

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយ លក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

**មាត្រា ៣៩.-**

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយ លក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។ ក្នុងករណីធ្លាប់ទទួលរងការផ្តន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើស ដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យទ្វេដង ។

**មាត្រា ៤០.-**

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយ លក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល ។

ក្នុងករណីធ្លាប់ទទួលរងការផ្តន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើសដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យទ្វេដង ។

**មាត្រា ៤១.-**

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយ លក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៨ ០០០ ០០០ (ប្រាំបីលាន) រៀល ទៅ ៤០ ០០០ ០០០ (សែសិបលាន) រៀល ។

ក្នុងករណីធ្លាប់ទទួលរងការផ្តន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើសដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យទ្វេដង ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង



www.pheakdeylaw.com

**មាត្រា ៤២.-**

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយលក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។

ក្នុងករណីធ្លាប់ទទួលរងការផ្តន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើសដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យទ្វេដង ។

**មាត្រា ៤៣.-**

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយលក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៨ ០០០ ០០០ (ប្រាំបីលាន) រៀល ទៅ ៤០ ០០០ ០០០ (សែសិបលាន) រៀល ។

ក្នុងករណីធ្លាប់ទទួលរងការផ្តន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើសដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យទ្វេដង ។

**មាត្រា ៤៤.-**

អំពើលក់ ឬចែកចាយផលិតផលថ្នាំជក់គ្រប់ប្រភេទដល់ជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ឬស្ត្រីដែលមានគភ៌ កាលបើគភ៌នោះត្រូវបានគេឃើញជាក់ស្តែង ឬកាលដែលខ្លួនបានដឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ១ ០០០ ០០០ (មួយលាន) រៀល ។

**មាត្រា ៤៥.-**

រាល់បរិមាណ ចំនួនបារី ឬផលិតផលថ្នាំជក់ដែលត្រូវបានបញ្ញត្តហាមឃាត់ដោយមាត្រា ១៦ នៃច្បាប់នេះ ត្រូវរឹបអូសដោយមន្ត្រីមានសមត្ថកិច្ច ។

**មាត្រា ៤៦.-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ១ ០០០ ០០០ (មួយលាន) រៀល ចំពោះអំពើលក់ ឬចែកចាយផលិតផលថ្នាំជក់គ្រប់ប្រភេទ នៅក្នុងបរិវេណនៃគ្រឹះស្ថានសិក្សា គ្រឹះស្ថានសុខាភិបាល សួនកុមារ គ្រឹះស្ថានសាសនា សារមន្ទីរ រមណីយដ្ឋានប្រវត្តិសាស្ត្រ កន្លែងហាត់ប្រាណ ស្ថានីយ ប្រេងឥន្ធនៈ និងកន្លែងងាយឆាបឆេះ ។

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០ ០០០ (ពីរសែន) រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល ចំពោះអំពើលក់ផលិតផលថ្នាំជក់គ្រប់ប្រភេទតាមមធ្យោបាយមិនផ្ទាល់ តាមរយៈម៉ាស៊ីនលក់ដោយស្វ័យប្រវត្តិ តាមការបញ្ជាទិញតាមប្រៃសណីយ៍ និងតាមការបញ្ជាទិញតាមសេវាទូរគមនាគមន៍ផ្សេងៗ ។

**មាត្រា ៤៧.-**

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៣៨ ដល់មាត្រា ៤៣ និងកថាខណ្ឌទី ២ មាត្រា ៤៦ នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវពិន័យជាប្រាក់ទ្វេដង ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ ៖

១- ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

២- ការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមព្រហ្មទណ្ឌ ។

៤- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមព្រហ្មទណ្ឌ ។

៥- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍) នៃក្រមព្រហ្មទណ្ឌ ។

## ជំពូកទី ១២
## អន្តរប្បញ្ញត្តិ

**មាត្រា ៤៨.-**

បទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យផលិតផលថ្នាំជក់ ដែលនៅជាធរមាន នៅមានសុពលភាពរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។



www.pheakdeylaw.com

## ជំពូកទី ១៣
## អវសានប្បញ្ញត្តិ

**មាត្រា ៤៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០១៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកម.១៥០៥.៤៥៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**
**ហត្ថលេខា**
**ម៉ម ប៊ុនហេង**

លេខ: ៤៦៥ ស.ណ
**សំណៅដែលមានសេចក្តីដូចច្បាប់ដើម**
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊ុយ សុខា**

www.phealdeylaw.com